ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ៧៦ ត្រីមាសទី ០៤ ឆ្នាំ ២០១៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៦-១០-២០១៧	-ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧០៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ជូ អ៊ីជាំង** (ZHU YUJIANG) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរមកជាឈ្មោះ **ជូ ចំរើន** (CHOU CHAMROEUN)	៨២៥៦
០៦-១០-២០១៧	-ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧០៧ ស្តីពី ការតែងតាំងឯកឧត្តម **លឹម មុនិន្ទ** និងលោក **ឡេង សំណាង** ជា ឧកញ៉ា	៨២៥៧
០៦-១០-២០១៧	-ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧០៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **កេង សុម៉ារិទ្ធ** ជានាយកសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ	៨២៥៨
០៦-១០-២០១៧	-ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧០៩ ស្តីពី ការតែងតាំងលោកជំទាវ **តឹក លក្ខិណា** ជាអនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ	៨២៥៩
០៦-១០-២០១៧	-ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧១០ ស្តីពី ការតែងតាំងមន្ត្រីចំនួន ០២ រូប ជាអនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន	៨២៦០
០៦-១០-២០១៧	-ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧១១ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហានថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៥ រូប	៨២៦១
០៦-១០-២០១៧	-ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧១២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហានថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៥២ រូប	៨២៦២
០៦-១០-២០១៧	-ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧១៣ ស្តីពី ការតែងតាំងឯកឧត្តម **ងួន រតនៈ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៥ ឱ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង	៨២៦៥
០៦-១០-២០១៧	-ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧១៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ អស់លោក ចំនួន ០៧ រូប	៨២៦៦

០៧-១០-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧១៥ ស្តីពី ការផ្តល់ឋានៈ ដល់ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ម ប៊ុនហេង** ជាសាស្ត្រាចារ្យមហាបរិញ្ញា នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ៨២៦៧

០៧-១០-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧១៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ដល់មន្ត្រី ចំនួន ០២ រូប ជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ៨២៦៨

០៧-១០-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧១៧ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **Kim Jae Youl** ជាទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ដោយមិនយកប្រាក់បៀវត្ស ៨២៦៩

០៧-១០-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧១៨ ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ជាករណីពិសេស ដល់ឯកឧត្តម **ចាន់ សុខុម** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួង ពាណិជ្ជកម្ម ៨២៧១

០៧-១០-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/១០១៧/៧១៩ ស្តីពីការតែងតាំងឯកឧត្តម **ចាន់ សុខុម** ជា អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៨២៧២

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

០៤-១០-២០១៧ -អនុក្រឹត្យលេខ ១៦៥ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់វិទ្យាស្ថាន ពហុបច្ចេកទេសមិត្តភាព កម្ពុជា ចិន ខេត្តព្រះសីហនុ ៨២៧៣

០៤-១០-២០១៧ -អនុក្រឹត្យលេខ ១៦៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៨២៧៧

១០-១០-២០១៧ -អនុក្រឹត្យលេខ ១៦៧ អនក្រ.បក ស្តីពី ការកំណត់តំបន់សហគមន៍ នៃឧទ្យានជាតិ ព្រះមុនីវង្ស "បូកគោ" លើផ្ទៃដីទំហំ ៤១,៥៣ ហិកតា ស្ថិតក្នុងភូមិសាស្ត្រ ភូមិទទឹងថ្ងៃ ឃុំបឹងទូក និងទំហំ ៧,០៧ ហិកតា ក្នុងភូមិព្រៃកចេក ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ៨២៧៩

០៩-១០-២០១៧ -អនុក្រឹត្យលេខ ១១៣៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨២៨៣

០៩-១០-២០១៧ -អនុក្រឹត្យលេខ ១១៣៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨២៨៤

១០-១០-២០១៧ -អនុក្រឹត្យលេខ ១១៣៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៨២៨៦

១០-១០-២០១៧ -អនុក្រឹត្យលេខ ១១៣៧ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៨៣១០

គ

២~សេចក្ដីសម្រេច

១១-១០-២០១៧ -សេចក្ដីសម្រេចលេខ ៩០ សសរ ស្ដីពី ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំពិធីបុណ្យសមុទ្រឆ្នាំ ២០១៧ ចាប់ពីថ្ងៃទី ២២ ដល់ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៧ នៅខេត្តកែប ក្រោមប្រធានបទៈ ឆ្នេរសមុទ្របៃតង ៖ អនាគត គឺ បច្ចុប្បន្ន ៨៣១១

១៣-១០-២០១៧ -សេចក្ដីសម្រេចលេខ ៩១ សសរ ស្ដីពី ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៨៣២៣

III~ការងារបណ្ដាក្រសួង

១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៣-០៨-២០១៧ -ប្រកាសលេខ ៧៧២ សហវ.ប្រក ស្ដីពី ការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាល នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ *(តមកពី រាជកិច្ចលេខ ៧៥)* ៨៣២៥

២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

០២-១០-២០១៧ -សេចក្ដីសម្រេចលេខ ៤៦៤៤ សសរ ស្ដីពី ការលុបឈ្មោះគណបក្សដែលបានបង្កើតនៅក្រសួងមហាផ្ទៃ ៨៣៦៤

០២-១០-២០១៧ -សេចក្ដីសម្រេចលេខ ៤៦៤៥ សសរ ស្ដីពី ការលុបឈ្មោះគណបក្សដែលបានបង្កើតនៅក្រសួងមហាផ្ទៃ ៨៣៦៥

០២-១០-២០១៧ -សេចក្ដីសម្រេចលេខ ៤៦៤៦ សសរ ស្ដីពី ការលុបឈ្មោះគណបក្សដែលបានបង្កើតនៅក្រសួងមហាផ្ទៃ ៨៣៦៦

នស/រកត/១០១៧/៧០៦

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជូ អ៊ីជាំង** (ZHU YUJIANG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៦២ នៅខេត្តជាំងស៊ី សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរមកជាឈ្មោះ **ជូ ចំរើន** "CHOU CHAMROEUN" ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរប. ១៧១០.៧១៥

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៧

លេខៈ ៧០៣ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ .ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/ ៧០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

តែងតាំង :

ឯកឧត្តម លឹម មុនិន្ទ
លោក ឡេង សំណាង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរពា ១៧/១០.៧/១៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៧

លេខៈ ៧១៣ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

នស/រកត/១០១៧/ ៧០៨

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម **កេង សុម៉ារិទ្ធ** ជានាយកសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានឋានៈស្មើអនុរដ្ឋលេខាធិការ។

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.ស. ១៧១០. ៧១៧

លេខ: ៧០៨ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៧

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/៧០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម /១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោកជំទាវ **តឹក លក្ខិណា** ជាអនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.១៧.១៧/១០.១៧

លេខ: ៧០៧ ស.ណ

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៧

សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/៧៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងមន្ត្រីចំនួន ០២ រូប :

១-ឯកឧត្តម **ជឹម លាវ** ជា **អនុរដ្ឋលេខាធិការ** ក្រសួងព័ត៌មាន

២-លោកជំទាវ **ស៊ី វណ្ណថា** ជា **អនុរដ្ឋលេខាធិការ** ក្រសួងព័ត៌មាន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.១៧១០.៧១៩

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៧

លេខ: ៧០៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/៧៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក

១-ឧត្តមសេនីយ៍ទោ **ហួត ឈាងអន** អត្តលេខ ០២០០៥៩
២-ឧត្តមសេនីយ៍ទោ **នៃ គន្ធ** អត្តលេខ ០១៥៣០៦
៣-ឧត្តមសេនីយ៍ទោ **ហែម ថា** អត្តលេខ ០០០៤៤២

ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី **សុខ សារាគល** អត្តលេខ ០០២៨៣២
២-ឧត្តមសេនីយ៍ត្រី **ព្រហ្ម ពិសិដ្ឋ** អត្តលេខ ០២២៤២៥

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.៣. ១៧/១០.៧/២០

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៧

លេខ: ៧០៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/ ៧៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក

១-ឧត្តមសេនីយ៍ទោ **ឈឹម សុភន** អត្តលេខ ០០៨៩៩១
២-ឧត្តមសេនីយ៍ទោ **ខាត់ សុផល** អត្តលេខ ០០១៧២២

ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី **ឡៀប ផាណ្ណា** អត្តលេខ ០០២១៩៩
២-ឧត្តមសេនីយ៍ត្រី **ធួន សុធីរ** អត្តលេខ ០១៣៩១៨
៣-ឧត្តមសេនីយ៍ត្រី **នង ផាល់** អត្តលេខ ០០១៥៥៦
៤-ឧត្តមសេនីយ៍ត្រី **ឈឹម ធិតរ្យិទ្ធី** អត្តលេខ ០២១៧៤២
៥-ឧត្តមសេនីយ៍ត្រី **លី ម៉ិនឆាយ** អត្តលេខ ០០០៩៧៥
៦-ឧត្តមសេនីយ៍ត្រី **សេក ចន្ថា** អត្តលេខ ០០៨៤១៥
៧-ឧត្តមសេនីយ៍ត្រី **សួស សទ្ធា** អត្តលេខ ០២៤៨១៤

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៨-ឧត្តមសេនីយ៍ត្រី សួន សុង អត្តលេខ ០០៨៥៧៦

៩-ឧត្តមសេនីយ៍ត្រី កៅ សុខន អត្តលេខ ០០១៥៧៦

១០-ឧត្តមសេនីយ៍ត្រី និត្យ សុវណ្ណតារា អត្តលេខ ០០៤២៦២

១១-ឧត្តមសេនីយ៍ត្រី សំ សុធារិទ្ធ អត្តលេខ ២១៩៦៨៤

១២-ឧត្តមសេនីយ៍ត្រី កុល វ៉េត អត្តលេខ ០២៤៧៩៣

១៣-ឧត្តមសេនីយ៍ត្រី ពៅ ប៊ុនធន អត្តលេខ ០០៣៨៤៨

១៤-ឧត្តមសេនីយ៍ត្រី សូ សំណាង អត្តលេខ ០២៤៨៣៩

១៥-ឧត្តមសេនីយ៍ត្រី អ៊ិត សារ៉េន អត្តលេខ ០៤៨១២៥

១៦-ឧត្តមសេនីយ៍ត្រី ឃុត សុចិត្រា អត្តលេខ ០៣១៣៨៤

១៧-ឧត្តមសេនីយ៍ត្រី រស់ សំអាត អត្តលេខ ០១៩៧២៦

១៨-ឧត្តមសេនីយ៍ត្រី សុខ ប៊ុនធឿន អត្តលេខ ០៤៣៤៦០

១៩-ឧត្តមសេនីយ៍ត្រី ឈាង វណ្ណវិជ្ជបុត្រ អត្តលេខ ០៣៧៦៤៣

២០-ឧត្តមសេនីយ៍ត្រី ហ៊ួន ចំរើន អត្តលេខ ១០០៧៩១

២១-ឧត្តមសេនីយ៍ត្រី ឈាង វណ្ណវិជ្ជវត្តិ អត្តលេខ ០៣៧៦៤១

គ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក អ៊ូ សុខ អត្តលេខ ០១៤៥៣៩

២-វរសេនីយ៍ឯក ឱក ចាន់ធី អត្តលេខ ០២៤៨៧៥

៣-វរសេនីយ៍ឯក ចាន់ ស៊ីថា អត្តលេខ ០០៨៤២២

៤-វរសេនីយ៍ឯក ខៀម ដា អត្តលេខ ០០៨៤១៧

៥-វរសេនីយ៍ឯក លី ប៊ុនធឿន អត្តលេខ ០០៨៤២៥

៦-វរសេនីយ៍ឯក ញឹក ដារុធ អត្តលេខ ០០៨៤០១

៧-វរសេនីយ៍ឯក ចិត្រ សុធាវ៉ា អត្តលេខ ០៤៨១៤៨

៨-វរសេនីយ៍ឯក សារឹម ឡាលុយណា អត្តលេខ ០១១៨៤០

៩-វរសេនីយ៍ឯក ម៉ែន សុគន្ធ អត្តលេខ ០១៧៨០១

១០-វរសេនីយ៍ឯក មាស ប៊ុនឡី អត្តលេខ ០៣៨១១៩

១១-វរសេនីយ៍ឯក គង់ ម៉េង អត្តលេខ ០១៣៩៨៨

១២-វរសេនីយ៍ឯក ឃិន សុវណ្ណ អត្តលេខ ០១៧៨០០

១៣-វរសេនីយ៍ឯក ឡុង សុខធួន អត្តលេខ ០១៧៧៨៦

១៤-វរសេនីយ៍ឯក ឡោ សុវណ្ណវិចិត្រ អត្តលេខ ០១៧២៨១

១៥-វរសេនីយ៍ឯក យក់ គង់ អត្តលេខ ០៤៣១៧៩

១៦-វរសេនីយ៍ឯក ឡុង សេង អត្តលេខ ០៣៨០១៣

១៧-វរសេនីយ៍ឯក យឹម សម្បត្តិរតនា អត្តលេខ ០៤៣០៣៩

១៨-វរសេនីយ៍ឯក ចន្ទន៍ ពិសិដ្ឋ អត្តលេខ ០០១៨៣០

១៩-វរសេនីយ៍ឯក កែវ ផល្លី អត្តលេខ ០១៤៦៧២

២០-វរសេនីយ៍ឯក ហាង ប៊ុនឡុង អត្តលេខ ០១៣៩០៨

២១-វរសេនីយ៍ឯក ហាង សុវណ្ណចន្ទ្រា អត្តលេខ ០៤៣០៧៥

២២-វរសេនីយ៍ឯក ទេព វិបុល អត្តលេខ ១៤៥៤៧៥

២៣-វរសេនីយ៍ឯក ឡុង ណារិន អត្តលេខ ០៦៧៧០២

២៤-វរសេនីយ៍ឯក **ហេង ចណ្ណសក្តិ** អត្តលេខ ០២០៨៥២
២៥-វរសេនីយ៍ឯក **ឆាយ មិន** អត្តលេខ ០១៧៧៧៨
២៦-វរសេនីយ៍ឯក **ផាន់ មូខ្សៀន** អត្តលេខ ០៣១៣៨៩
២៧-វរសេនីយ៍ឯក **ម៉ុង សិរីចុឡ្យង់** អត្តលេខ ០១៤២៣៧
២៨-វរសេនីយ៍ឯក **មិន ណាចុឡ្យ** អត្តលេខ ០០៤៧៣៥
២៩-វរសេនីយ៍ឯក **កៅ ចណ្ណា:** អត្តលេខ ០៤៣០៦៤

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.១៧១០.៧៤១

លេខ: ៧១៦ ស.ណ

សំណៅចែលមានតម្លៃជាការចែកផ្សាយ

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៧

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/៧/១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៦៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យចូលនិវត្តន៍ មន្ត្រីរាជការស៊ីវិល របស់ក្រសួង-ស្ថាប័ន ចំនួន ២៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ខួន រតនៈ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៧/១២ ស.ណ
សំណៅចែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី១០ ខែ១៧ ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

៣៧៧.១៧/១០.៧២២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៧

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/៧៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍:

១- លោក	ហឺ លីពីង(HE LEPING)	ជាប្រធានក្រុមប្រឹក្សាភិបាល
២- លោក	ចាំង ជៀនប៊ីន(ZHANG JIANBIN)	ជាសមាជិកនៃក្រុមប្រឹក្សាភិបាល
៣- លោក	ឌឹង លី(DENG LI)	ជាសមាជិកនៃក្រុមប្រឹក្សាភិបាល
៤- លោក	ឌួយ ជុនលីង(CUI JUNLING)	ជាប្រធានក្រុមការងារសំណង់
៥- លោក	លូ ស៊ីនយ៉ឺន(LIU XINYUN)	ជាសមាជិកនៃក្រុមប្រឹក្សាភិបាល
៦- លោក	ហ្វាំង ហឺ(HUANG HE)	ជាសមាជិកនៃក្រុមប្រឹក្សាភិបាល
៧- លោក	ស៊ូ នីង(XU NING)	ជាជំនួយការក្រុមប្រឹក្សាភិបាល

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ឈ៧. ១៧១០. ៧៤៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៧

លេខ: ៧១១ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/ ៧៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/០៩២ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៣ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ផ្តល់ឋានៈដល់ ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ម ប៊ុនហេង** ជាសាស្ត្រាចារ្យមហាបរិញ្ញា នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរក. ១៧១០.៧២៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧

លេខ: ៧២០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ១១ ខែ ១០ ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/៧១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង និងផ្តល់ឋានៈ ដល់មន្ត្រីចំនួន ០២ រូប ៖

១-ឯកឧត្តម **ផុស សុវណ្ណ** ជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ មានឋានៈស្មើ **រដ្ឋលេខាធិការ**

២-ឯកឧត្តម **ទន់ សារ៉ាត** ជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.១៧១០.៧២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧

លេខ: ៧១៩ ស.ណ
សំណៅដែលមានគន្លែងជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/៧១៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ភោធាតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០, មាត្រា១១, មាត្រា១២, មាត្រា១៤, មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ប្រកាសបទ្ទាប់

មាត្រា១.- តែងតាំងនិងផ្តល់ឋានៈឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **Kim Jae Youl** ជាទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយមិនយកប្រាក់បៀវត្ស ។

មាត្រា២.- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរក ១៧១០.៧២៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧

លេខៈ៧២៥ ស.ណ

សំណៅចែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/ ៧១៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ប្តូរប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ជាករណីពិសេសដល់ ឯកឧត្តម **ចាន់ សុខុម** ពីឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ថ្នាក់លេខ ៨ នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល មកឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងពាណិជ្ជកម្ម ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

៣៧៧.១៧១០.៧២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧

លេខៈ ៧១៨ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ១០ ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១៧/៧១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ចាន់ សុខុម** ជាអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧. ១៧១០. ៧២៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៧

លេខ: ៧១៧ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានពហុបច្ចេកទេសមិត្តភាព កម្ពុជា ចិនខេត្តព្រះសីហនុ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ./.

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ត្រូវបានបង្កើតវិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជា ចិន ខេត្តព្រះសីហនុ ដែលសរសេរជាអក្សរកាត់ថា **វ.ព.ម.ក.ច.ព.** និងជាភាសាអង់គ្លេសថា **Preah Sihanouk Cambodia China Friendship Poly technic Institute** សរសេរជាអក្សរកាត់ថា **P.C.C.F.P.I.**។

មាត្រា២ .-

វ.ព.ម.ក.ច.ព. ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

វ.ព.ម.ក.ច.ព. មានទីតាំងស្ថិតនៅភូមិពូធឿង ឃុំបិតត្រាង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

ជំពូកទី២
តួនាទីនិងភារកិច្ច

មាត្រា៣ .-

វ.ព.ម.ក.ច.ព. មានតួនាទីជាសេនាធិការឲ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានភារកិច្ចដូចខាងក្រោម៖

- អភិវឌ្ឍកម្មវិធីអប់រំនិងបណ្តុះបណ្តាលស្របតាមស្តង់ដាសមត្ថភាព ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងតម្រូវការទីផ្សារការងារ
- កសាងនិងអនុវត្តផែនការអភិវឌ្ឍរបស់វិទ្យាស្ថានរយៈពេលខ្លី មធ្យម និងវែង
- សិក្សា ស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិនិងអន្តរជាតិ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេសនិងប្រឹក្សាយោបល់ដល់មន្ត្រីនិងគ្រូបច្ចេកទេស
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការរបស់វិទ្យាស្ថាន
- គ្រប់គ្រងបុគ្គលិក គ្រូបង្រៀន គ្រូបច្ចេកទេស កម្មករ សិក្ខាកាម សិស្ស និស្សិត និងទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន
- កៀរគរធនធានពីប្រភពផ្សេងៗទៀតសម្រាប់ការបណ្តុះបណ្តាលនិងការសិក្សាស្រាវជ្រាវ
- ជ្រើសរើសសិក្ខាកាម សិស្ស និស្សិតឲ្យចូលរៀនតាមការកំណត់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា៤ .-

វ.ព.ម.ក.ច.ព. ធ្វើការបណ្តុះបណ្តាលដោយអនុលោមតាមក្របខណ្ឌគុណវុឌ្ឍិជាតិក្រើកម្រិតជំនាញដូចខាងក្រោម៖

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ សិក្សារយៈពេល១ឆ្នាំ ២ឆ្នាំ ឬ៣ឆ្នាំ ដែលមានយ៉ាងតិច៣០ក្រេឌីត(សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា ឯកទេស ឬសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច១២០ក្រេឌីត។

យន្តការ នីតិវិធី និងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ជំពូកទី៣
រចនាសម្ព័ន្ធនិងការគ្រប់គ្រង

មាត្រា៥ .-

វ.ព.ម.ភ.ច.ព. ត្រូវដឹកនាំដោយនាយក១(មួយ)រូប មានឋានៈស្មើនឹងប្រធាននាយកដ្ឋាននិងនាយករងមួយចំនួនមានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋាន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

វ.ព.ម.ភ.ច.ព. មានដេប៉ាតឺម៉ង់និងការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់និងការិយាល័យចំណុះ **វ.ព.ម.ភ.ច.ព.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា៦ .-

វ.ព.ម.ភ.ច.ព. មានក្រុមប្រឹក្សាបច្ចេកទេសមួយដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាល ស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីសិក្សារបស់ **វ.ព.ម.ភ.ច.ព.**។

សមាសភាពនិងភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា៧ .-

វ.ព.ម.ភ.ច.ព. អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនសម្រាប់ជួយបំពេញការងារ។

មាត្រា៨ .-

វ.ព.ម.ភ.ច.ព. មានសិទ្ធិប្រើត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

មាត្រា៩ .-

សិក្ខាកាម សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយ **វ.ព.ម.ភ.ច.ព.** និងត្រូវទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា១០ .-

ការចំណាយសម្រាប់ដំណើរការរបស់ **ទ.ព.ម.ភ.ច.ព.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ទ.ព.ម.ភ.ច.ព. មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

ជំពូកទី៤
អវសានប្បញ្ញត្តិ

មាត្រា១១ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

អ៊ិត សំហេង

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តព្រះសីហនុ
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ១៦៦ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១.-

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៤៦ ៨០០ ០០០ រៀល (សែសិបប្រាំមួយលានប្រាំបីរយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ជូនក្រសួងមហាផ្ទៃ (សន្តិសុខសាធារណៈ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

មាត្រា២.-

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ផ្តល់ជូនប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ចំនួន ១៣ ប៉ុស្តិ៍ ដែលទើបបង្កើតថ្មី។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៧ ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកំណត់តំបន់សហគមន៍នៃឧទ្យានជាតិព្រះមុនីវង្ស"បូកគោ" លើផ្ទៃដីទំហំ៤១,៥៣ហិកតា ស្ថិតក្នុងភូមិសាស្រ្ត ភូមិទទឹងថ្ងៃ ឃុំបឹងទូក និងទំហំ៧,០៧ហិកតា ក្នុងភូមិព្រែកចេក ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សម្រេច

មាត្រា១.-

ត្រូវបានកំណត់ជាតំបន់សហគមន៍ នៃឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" លើផ្ទៃដីទំហំ៤១,៥៣ ហិកតា (សែសិបមួយហិកតានិងហាសិបបីអា) សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋាន ស្ថិតក្នុងភូមិសាស្ត្រភូមិទទឹងថ្ងៃ ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត ដែលមានផែនទីកំណត់ទីតាំងជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងចំណុចនិយាមកាដូចខាងក្រោម៖

No	X	Y	No	X	Y
1	403839	1173154	13	404140	1172372
2	403866	1173212	14	404091	1172562
3	403778	1173222	15	404090	1172679
4	403719	1173339	16	404062	1172722
5	403508	1173331	17	404010	1172770
6	403582	1173042	18	403990	1172826
7	403951	1172000	19	403990	1172888
8	404247	1172148	20	403985	1172938
9	404224	1172187	21	403964	1172976
10	404200	1172232	22	403930	1173003
11	404176	1172284	23	403920	1173089
12	404150	1172336			

មាត្រា២.-

ត្រូវបានកំណត់ជាតំបន់សហគមន៍ នៃឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" លើផ្ទៃដីទំហំ៧,០៧ ហិកតា (ប្រាំពីរហិកតានិងសូន្យប្រាំពីរអា) សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានស្ថិតក្នុងភូមិសាស្ត្រភូមិព្រែករចេក ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ដែលមានផែនទីកំណត់ទីតាំងជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងចំណុចនិយាមកាដូចខាងក្រោម៖

No	X	Y	No	X	Y
1	397665	1170070	3	397311	1170457
2	397617	1170328	4	397313	1170237

មាត្រា៣.-

តំបន់សហគមន៍ នៃឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ស្ថិតក្នុងភូមិសាស្ត្រ ភូមិទទឹងថ្ងៃ ឃុំបឹងទូក និងភូមិព្រែកចេក ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ត្រូវបានកំណត់ជាតំបន់គ្រប់គ្រងដែលបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលមានសកម្មភាពស្រាប់ រួមមានលំនៅដ្ឋាន ស្រែ ចំការ។ ការចេញប័ណ្ណដីធ្លី ការអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថានដោយអនុលោមតាមច្បាប់ភូមិបាល។

មាត្រា៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ: អនុក្រឹត្យលេខ ១៦៧ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៧

ផែនទីកំណត់តំបន់សហគមន៍ នៃឧទ្យានជាតិព្រះមុនីវង្ស -បូកគោ- លើផ្ទៃដីទំហំ ៤១.៥៣ ហិកតា ស្ថិតក្នុងភូមិសាស្ត្រ ភូមិទទឹងថ្ងៃ ឃុំបឹងទូក និងទំហំ ៧.០៧ ហិកតា ក្នុងភូមិព្រែកចេក ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត



ចំណុចទិយាមកា តំបន់ A		
ID	Coor_X	Coor_Y
1	403893	1173154
2	403866	1173212
3	403778	1173222
4	403719	1173339
5	403508	1173331
6	403582	1173042
7	403951	1172000
8	404247	1172148
9	404224	1172187
10	404200	1172232
11	404176	1172284
12	404150	1172336
13	404140	1172372
14	404091	1172567
15	404090	1172679
16	404062	1172722
17	404010	1172770
18	403990	1172826
19	403990	1172888
20	403985	1172935
21	403964	1172976
22	403930	1173003
23	403970	1173089

ចំណុចទិយាមកា តំបន់ B		
ID	Coor_X	Coor_Y
1	397665	1170070
2	397617	1170328
3	397311	1170457
4	397313	1170237



រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៧

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៣៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១. បំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២ គ្រឿងជូនអង្គការ JHP និងស្ថានទូតអាមេរិកប្រចាំកម្ពុជា ដែលបានចូលរួមជួយកសាងអគារសិក្សា ជូនដល់សាលារៀនតាមបណ្តាខេត្តមួយចំនួន ក្នុងព្រះរាជាណាចក្រកម្ពុជា នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-អ្នកស្ថាបនិកឆ្នើម (Great Builders) បានផ្តល់ថវិកាចំនួន ៤៩,៩៧៤ ដុល្លារអាមេរិក ជួយកសាងអគារសិក្សា ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនសាលាល្វាទង ស្ថិតនៅភូមិល្វាទង ឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ។

ខ-ស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា បានផ្តល់ថវិកាចំនួន ២៣៦,២៨៤.៧ ដុល្លារអាមេរិក ជួយកសាងអគារសិក្សាចំនួន ០១ ខ្នង មាន ០៧ បន្ទប់ ជូនដល់វិទ្យាល័យសម្តេចឪ សម្តេចម៉ែបរសេដ្ឋ ស្ថិតនៅភូមិតាន្ទូន ឃុំពោធិម្រាល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អភិបាលនៃគណៈអភិបាលខេត្តក្រចេះ កំពង់ស្ពឺ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...១១៣៥...អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
